**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No. 08 PR-23/EoJ                                        27 February 2023

## Japan Provides US$843,946 for Raising Awareness of Environment Issues, Promoting Remedial Study and Developing Quality University for Physical Education through ICT

The Government of Japan will provide US$843,946 in total for three recipient organizations under the framework, *the Grant Assistance for Japanese NGO Projects*. The Grant Contract was signed today between H.E. Mr. UENO Atsushi, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the three recipients respectively, to carry out the following projects:

1. ‘Realization of sustainable life environment around Cambodian citizens through promoting and raising awareness of environment issues (Year 3)’ (US$110,035)
Recipient: Non-profit organization Nature Center Risen
In this project, Nature Center Risen will promote and increase fundamental environmental awareness across Cambodia by providing educational materials and equipment to improve environmental literacy of the citizens and implementing awareness-raising activities. Also, the organization will conduct trainings for environment education in collaboration with pagodas, health centers, the Ministry of Environment of Cambodia and Provincial Department of Environment. Through this project, about 320 people will be able to play a core role in promoting and raising awareness of the citizens toward environmental issues. This is expected to help improve the living environment across Cambodia.

2. ‘The Project to Promote Remedial Study for Remote Primary School in Cambodia’ (US$263,656)
Recipient: Shanti Volunteer Association: SVA
In this project, Shanti Volunteer Association aims to establish learning facilities which can be utilized for remedial and self-study at two primary schools in Pursat province. This educational facility will be composed of self-study room and library, and the digital educational materials

will be equipped too. Also, the organization will conduct various training activities for teachers, school management committee, and parents to support and promote remedial learning. Through this project, 673 students, teachers and parents in total at the targeted areas will be benefited.

3. 'Project on Developing 4-year Quality Physical Education Teacher Education University through Utilizing ICT (Year 1)' (US$470,255)
Recipient: Non-Profit Organization Hearts of Gold

In this project, Hearts of Gold will collaborate with National Institute of Physical Education and Sport (NIPES) to improve 7 important management systems: library operation, international center establishment, internal quality assurance, teacher development, student management, alumni support and security management, by utilizing ICT facility. Through this project, approximately 70 staff and 180 teacher trainees in the institute will be able to gain better learning environment for physical education. Also over 1,000,000 students in Cambodia are expected to receive more effective physical education.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided over US$50 million for 149 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161, fax: 023-214-330*
*Email: eco.jpn@.pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសពត៌មាន**

លេខ. 08 PR-23/EoJ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ជប៉ុនផ្តល់ថវិកា ៨៤៣,៩៤៦ ដុល្លារអាមេរិក**
**សម្រាប់ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាបរិស្ថាន ការលើកកម្ពស់ការសិក្សាបំប៉នបន្ថែម**
**និងការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សាដែលមានគុណភាពសម្រាប់ការអប់រំកាយ**
**តាមរយៈបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍**

រដ្ឋាភិបាលជប៉ុន នឹងផ្តល់ថវិកាសរុបចំនួន **៨៤៣,៩៤៦ ដុល្លារអាមេរិក** ដល់អង្គភាពទទួលជំនួយចំនួនបី ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងស្ថាប័នទទួលជំនួយទាំងបី សម្រាប់អនុវត្តគម្រោងដូចតទៅ៖

**១. គម្រោងការសម្រេចឱ្យបាននូវបរិស្ថានរស់នៅប្រកបដោយចីរភាពរបស់ប្រជាពលរដ្ឋកម្ពុជាតាមរយៈការលើកកម្ពស់ និងអប់រំការយល់ដឹងអំពីបញ្ហាបរិស្ថាន (ឆ្នាំទី៣) (ថវិកាជំនួយ ១១០,០៣៥ ដុល្លារអាមេរិក)**
**ស្ថាប័នទទួលជំនួយ៖ អង្គការមិនរកប្រាក់ចំណេញ** Nature Center Risen

នៅក្នុងគម្រោងនេះ អង្គការ Nature Center Risen នឹងលើកកម្ពស់ និងបង្កើនការយល់ដឹងជាមូលដ្ឋានអំពីបរិស្ថាន នៅទូទាំងប្រទេសកម្ពុជា តាមរយៈការផ្តល់សម្ភារៈ និងឧបករណ៍អប់រំ ដើម្បីកែលម្អចំណេះដឹងផ្នែកបរិស្ថានរបស់ប្រជាពលរដ្ឋ និងការអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹង។ មិនតែប៉ុណ្ណោះ អង្គការនឹងបើកវគ្គបណ្តុះបណ្តាលសម្រាប់ការអប់រំអំពីបរិស្ថាន ដោយសហការជាមួយវត្តអារាម មណ្ឌលសុខភាព ក្រសួងបរិស្ថាននៃប្រទេសកម្ពុជា និងមន្ទីរបរិស្ថានខេត្ត។ តាមរយៈគម្រោងនេះ ប្រជាពលរដ្ឋប្រមាណ ៣២០ នាក់ នឹងអាចដើរតួនាទីស្នូលក្នុងការលើកកម្ពស់ និងអប់រំការយល់ដឹងរបស់ប្រជាពលរដ្ឋទៅលើបញ្ហាបរិស្ថាន។ យើងរំពឹងថាគម្រោងនេះនឹងជួយកែលម្អបរិស្ថានរស់នៅទូទាំងប្រទេសកម្ពុជា។

**២. គម្រោងលើកកម្ពស់ការសិក្សាបំប៉នបន្ថែមសម្រាប់សាលាបឋមសិក្សានៅតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា (ថវិកាចំនួន ២៦៣,៦៥៦ ដុល្លារអាមេរិក)**
**ស្ថាប័នទទួលជំនួយ៖ អង្គការសន្តិស្ម័គ្រចិត្ត (SVA)**

ក្នុងគម្រោងនេះ អង្គការសន្តិស្ម័គ្រចិត្តមានគោលបំណងបង្កើតបរិក្ខារសិក្សា ដែលអាចប្រើប្រាស់សម្រាប់ការសិក្សាបំប៉នបន្ថែមនិងស្វ័យសិក្សា នៅសាលាបឋមសិក្សាចំនួនពីរ ក្នុងខេត្តពោធិ៍សាត់។ បរិក្ខារអប់រំនេះ រួមមានបន្ទប់ស្វ័យសិក្សា និងបណ្ណាល័យ ហើយសម្ភារៈសិក្សាបែបឌីជីថលក៏នឹងត្រូវបានបំពាក់ផងដែរ។ ជាមួយគ្នានេះ អង្គការនឹងអនុវត្តសកម្មភាពបណ្តុះបណ្តាលផ្សេងៗសម្រាប់គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលា និងមាតាបិតា ដើម្បីគាំទ្រ និងលើកកម្ពស់ការសិក្សាបំប៉នបន្ថែម។ សិស្សានុសិស្ស លោកគ្រូ អ្នកគ្រូ និងមាតាបិតា សរុបចំនួន ៦៧៣នាក់ នៅតាមតំបន់គោលដៅ នឹងទទួលបានអត្ថប្រយោជន៍តាមរយៈគម្រោងនេះ។

**៣. គម្រោងអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សាអប់រំគ្រូបង្រៀនអប់រំកាយដែលមានគុណភាពរយៈពេលបួនឆ្នាំតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាពត៌មាន និងសារគមនាគមន៍ (ឆ្នាំទី១) (ថវិកាចំនួន ៤៧០,២៥៥ ដុល្លារអាមេរិក)**
**ស្ថាប័នទទួលជំនួយ៖ អង្គការក្រៅរដ្ឋាភិបាល បេះដូងមាស**

នៅក្នុងគម្រោងនេះ អង្គការបេះដូងមាស នឹងសហការជាមួយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា (NIPES) ដើម្បីកែលម្អប្រព័ន្ធគ្រប់គ្រងសំខាន់ៗចំនួន៧ គឺ ប្រតិបត្តិការបណ្ណាល័យ ការបង្កើតមជ្ឈមណ្ឌលអន្តរជាតិ ការធានាគុណភាពផ្ទៃក្នុង ការអភិវឌ្ឍគ្រូបង្រៀន ការគ្រប់គ្រងសិស្ស ការគាំទ្រដល់អតីតសិស្ស និងការគ្រប់គ្រងសន្តិសុខ ដោយប្រើប្រាស់បរិក្ខារបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ តាមរយៈគម្រោងនេះ បុគ្គលិកប្រមាណ ៧០នាក់ និងសិក្ខាកាមគ្រូបង្រៀនចំនួន ១៨០នាក់ នៅក្នុងវិទ្យាស្ថាន នឹងអាចទទួលបានបរិស្ថានសិក្សាដែលប្រសើរជាងមុនសម្រាប់ការអប់រំកាយ។ មិនតែប៉ុណ្ណោះ យើងរំពឹងថាសិស្សានុសិស្សជាង ១,០០០,០០០នាក់ នៅក្នុងប្រទេសកម្ពុជា នឹងទទួលបានការអប់រំកាយដែលមានប្រសិទ្ធភាពជាងមុន។

ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជាតាំងពីឆ្នាំ ២០០២ ដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុនបានផ្តល់ថវិកាជាង៥០លានដុល្លារអាមេរិក ដល់គម្រោងចំនួន១៤៩ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតបឋមសិក្សា វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

---

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០
អ៊ីម៉ែល៖ *eco.jpn@pp.mofa.go.jp*
គេហទំព័រ៖ *http://www.kh.emb-japan.go.jp*

**សុន្ទរកថារបស់ ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី**
**ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យា**
**ផ្ដល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន**
**ថ្ងៃច័ន្ទ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២៣**

**ឈ្មោះគម្រោងទី១៖ គម្រោងការសម្រេចឱ្យបាននូវបរិស្ថានរស់នៅប្រកបដោយចីរភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់ និងអប់រំការយល់ដឹងអំពីបញ្ហាបរិស្ថាន (ឆ្នាំទី៣)**
**ស្ថាប័នទទួលជំនួយ៖ អង្គការមិនរកប្រាក់ចំណេញ** Nature Center Risen

**ឈ្មោះគម្រោងទី២៖ គម្រោងលើកកម្ពស់ការសិក្សាបំប៉នបន្ថែមសម្រាប់សាលាបឋមសិក្សានៅតំបន់ដាច់ស្រយាលក្នុងប្រទេសកម្ពុជា**
**ស្ថាប័នទទួលជំនួយ៖ អង្គការសន្តិស្ម័គ្រចិត្ត**

**ឈ្មោះគម្រោងទី៣៖ គម្រោងអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សាអប់រំគ្រូបង្រៀនអប់រំកាយដែលមានគុណភាពរយៈពេលបួនឆ្នាំ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ឆ្នាំទី១)**
**ស្ថាប័នទទួលជំនួយ៖ អង្គការក្រៅរដ្ឋាភិបាល បេះដូងមាស**

- សូមគោរព **លោកស្រី អ៊ីវ៉ាម៉ា មិយ៉ូកុ** នាយិកាអង្គការ Nature Center Risen
- **លោក កាសិ តាកាស៊ី** នាយកអង្គការសន្តិស្ម័គ្រចិត្តប្រចាំកម្ពុជា
- **លោក តិហ្សឹកា កូជិ** ប្រធានគម្រោងអង្គការបេះដូងមាសប្រចាំអាស៊ីអាគ្នេយ៍
- លោក លោកស្រី ភ្ញៀវកិត្តិយស ទាំងអស់ជាទីមេត្រី។

ថ្ងៃនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានរៀបចំពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្ដល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន ចំនួនបីគម្រោង។

រដ្ឋាភិបាលជប៉ុន បាននិងកំពុងផ្ដល់ជំនួយឥតសំណងដល់អង្គការក្រៅរដ្ឋាភិបាលជប៉ុន ចាប់តាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រគម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម របស់ពួកគេ ដែលត្រូវបានអនុវត្តនៅក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍ។ ក្នុងរយៈពេល២០ឆ្នាំចុងក្រោយនេះ ស្ថានទូតជប៉ុនបានផ្ដល់ជំនួយជាង១៤០គម្រោងនៅក្នុងប្រទេសកម្ពុជាតាមរយៈកម្មវិធីនេះ។ គម្រោងនីមួយៗបានចូលរួមចំណែកក្នុងការកែលម្អគុណភាពជីវិតរបស់ប្រជាជនកម្ពុជា។

ខ្ញុំសូមជម្រាបជូនដោយសង្ខេបអំពីគម្រោងទាំងបីដែលបានចុះហត្ថលេខានាថ្ងៃនេះដូចតទៅៈ

សម្រាប់គម្រោងទីមួយ រដ្ឋាភិបាលជប៉ុននឹងផ្ដល់ថវិកាប្រមាណ ១១០,០០០ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការ Nature Center Risen។ នៅក្នុងឆ្នាំទី៣ នៃគម្រោងនេះ ពួកគេនឹងអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីបញ្ហាបរិស្ថាន និងការបណ្ដុះបណ្ដាល នៅតាមវត្តអារាម និងមណ្ឌលសុខភាព ដោយប្រើប្រាស់សម្ភារៈអប់រំបរិស្ថានដែលទើបបង្កើតថ្មី និងឧបករណ៍អប់រំបរិស្ថានដែលផ្ដល់ជូនក្នុងឆ្នាំទី១ និងឆ្នាំទី២ នៃគម្រោង។ ជាមួយគ្នានេះ អង្គការនឹងទៅទស្សនកិច្ចខេត្តគំរូទាំង៦ ដែលពួកគេបានពិភាក្សា និងជ្រើសរើសជាមួយក្រសួងបរិស្ថាននៃប្រទេសកម្ពុជា ហើយនឹងតាមដានសកម្មភាពជាក់ស្ដែងនៅទីនោះ ជាមួយសាស្ត្រាចារ្យជប៉ុន និងមន្ត្រីក្រសួងបរិស្ថាន ដោយរំពឹងថាមន្ត្រីទាំងនោះ នឹងអាចអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងដល់ប្រជាពលរដ្ឋ ប្រកបដោយប្រសិទ្ធភាពបាន នាពេលអនាគត។ ខ្ញុំសង្ឃឹមថា តាមរយៈគម្រោងនេះ ប្រជាពលជនកម្ពុជាគ្រប់ជំនាន់ទាំងអស់ នឹងយល់ដឹងពីសារៈសំខាន់នៃការថែរក្សាបរិស្ថាន ដែលនឹងធ្វើឱ្យបរិស្ថានរស់នៅទូទាំងប្រទេសកម្ពុជាមានភាពប្រសើរឡើង។

សម្រាប់គម្រោងទីពីរ រដ្ឋាភិបាលជប៉ុននឹងផ្ដល់ថវិកាប្រមាណ ២៦០,០០០ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការសន្តិស្នេហ៍គ្រិស្ត។ នៅក្នុងគម្រោងនេះ ពួកគេនឹងសាងសង់បរិក្ខារសិក្សា ដែលរួមមានបន្ទប់ស្វ័យសិក្សា និងបន្ទប់បណ្ណាល័យ ដែលសិស្សអាចប្រើប្រាស់សម្ភារៈអប់រំបែបឌីជីថល ដើម្បីស្ដារការបាត់បង់ការសិក្សារបស់សិស្ស ដែលបង្កមកពីការបិទសាលារយៈពេលយូរ ក្នុងវិធានការការពារការឆ្លងរាលដាលនៃជំងឺកូវីដ១៩។ បន្ថែមពីនេះ អង្គការនឹងអនុវត្តសកម្មភាពបណ្ដុះបណ្ដាលសម្រាប់គ្រូបង្រៀន គណៈកម្មការគ្រប់គ្រងសាលារៀន និងមាតាបិតា ហើយព្យាយាមបង្កើតប្រព័ន្ធនិងបរិស្ថាន ដែលគ្រួសារនិងសហគមន៍ទាំងមូលអាចគាំទ្រដល់ការសិក្សារបស់សិស្ស។ ខ្ញុំសង្ឃឹមថា គម្រោងនេះនឹងបង្កើតបរិស្ថានសិក្សាសម្រាប់ការអនុវត្តការសិក្សាបំប៉នបន្ថែម និងស្វ័យសិក្សា ប្រកបដោយប្រសិទ្ធភាព ដែលនឹងពង្រឹងការលើកទឹកចិត្តរបស់សិស្សក្នុងការសិក្សារៀនសូត្រ និងសមត្ថភាពសិក្សារបស់ពួកគេ។

ជាចុងក្រោយ រដ្ឋាភិបាលជប៉ុននឹងផ្ដល់ថវិកាប្រមាណ ៤៧០,០០០ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការបេះដូងមាស។ អង្គការនេះ បាននិងកំពុងគាំទ្រដល់ការគ្រប់គ្រងមុខវិជ្ជាសិក្សាអប់រំកាយ ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងការដំឡើងបរិក្ខារអប់រំកាយ ដើម្បីធ្វើឱ្យវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា ដែលជាវិទ្យាស្ថានតែមួយគត់សម្រាប់បណ្ដុះបណ្ដាលគ្រូអប់រំកាយ និងកីឡានៅក្នុងប្រទេសកម្ពុជា ក្លាយជាគ្រឹះស្ថានឧត្តមសិក្សារយៈពេលបួនឆ្នាំសម្រាប់មុខវិជ្ជាសិក្សា

អប់រំកាយ។ ក្នុងឆ្នាំដំបូងនៃគម្រោងនេះ ដោយមានកិច្ចសហការជាមួយវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា អង្គការនឹងបង្កើតប្រព័ន្ធគ្រប់គ្រងដែលប្រសើរជាងមុន និងពង្រឹងប្រព័ន្ធរដ្ឋបាល ដោយប្រើប្រាស់បរិក្ខារបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ដើម្បីឱ្យវិទ្យាស្ថាននេះអាចផ្តល់ការបង្រៀនមុខវិជ្ជាសិក្សាអប់រំកាយរយៈពេលបួនឆ្នាំ ប្រកបដោយនិរន្តរភាព។ តាមរយៈគម្រោងនេះ ខ្ញុំសង្ឃឹមថាប្រព័ន្ធបណ្តុះបណ្តាល និងពង្រាយគ្រូបង្រៀនកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិប្រកបដោយនិរន្តរភាព នឹងត្រូវបានបង្កើតឡើង ហើយការអប់រំកាយនៅកម្ពុជានឹងមានភាពប្រសើរឡើង។

ខ្ញុំមានសេចក្តីសោមនស្សរីករាយដោយសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ទោះបីជាយ៉ាងណា ខ្ញុំក៏ទទួលស្គាល់ថានៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដើម្បីកែលម្អគុណភាពជីវិតរបស់ប្រជាជន។ រដ្ឋាភិបាលជប៉ុន បានផ្តល់កម្ចីហិរញ្ញប្បទាន សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតធំ ដូចជាការអភិវឌ្ឍកំពង់ផែស្វយ័តក្រុងព្រះសីហនុ និងការកែលម្អផ្លូវជាតិលេខ៥ ក៏ដូចជាសម្រាប់ការគាំទ្រដល់ការឆ្លើយតបបន្ទាន់ទៅនឹងវិបត្តិកូវីដ១៩ ជាមួយនឹងទឹកប្រាក់សរុបចំនួន ៤៥៣ពាន់លានយេន។ ជាមួយគ្នានេះ រដ្ឋាភិបាលជប៉ុនចាត់ទុកថា ការផ្តល់ការគាំទ្រនៅតាមតំបន់ជនបទ និងការធ្វើការជិតស្និទ្ធជាមួយប្រជាជនមូលដ្ឋានតាមរយៈជំនួយឥតសំណងសម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុន និងជំនួយឥតសំណងគូសាណូណិមានសារៈសំខាន់ស្មើគ្នាផងដែរ។ ប្រទេសជប៉ុននឹងបន្តសហការជាមួយអង្គការក្រៅរដ្ឋាភិបាលជប៉ុន និងគាំទ្រការងាររបស់ពួកគេ ដើម្បីដោះស្រាយបញ្ហាប្រឈមនានា។

សូមអរគុណសម្រាប់ការចូលរួមក្នុងពិធីចុះហត្ថលេខា នាថ្ងៃនេះ។ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និង សូមឱ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។ ខ្ញុំសូមបញ្ចប់សុន្ទរកថារបស់ខ្ញុំត្រឹមនេះ។

សូមអរគុណ។